# ព័ត៌មានសំរាប់មាតាបិតាអំពីការវះកាត់ពិនិត្យសពទារកដែលស្លាប់ពីកំណើត

**Information for parents about the post-mortem examination of a stillborn baby**

*នៅពេលទារករបស់អ្នកបានស្លាប់ពីកំណើត ការប៉ងប្រាថ្នា សេចក្ដីសង្ឃឹម និងការស្រមៃត្រូវខូចបាត់បង់អស់ ហើយជីវិត
របស់អ្នកក៏ត្រូវប្រែប្រួល។ មាតាបិតាជាច្រើនទទួលអារម្មណ៍តក់ស្លុត និងវង្វេងជាលើកដំបូងនៅពេលត្រូវគេប្រាប់ថាទារក
របស់ខ្លួនបានស្លាប់។ ទារកមិនសមនឹងត្រូវស្លាប់សោះ ក៏ប៉ុន្តែនៅពេលវាស្លាប់វិញ
នោះនឹងអាចធ្វើឲ្យកើតមានការរន្ធត់ចិត្តដ៏ លើសលប់ ហើយមានការឈឺចាប់ជាទីបំផុត។
នេះគឺជាទុក្ខព្រួយដ៏ធំធេងដែលទារករបស់អ្នកបានស្លាប់។*

*អ្នកប្រហែលមានសំនួរជាច្រើន ហើយនឹងត្រូវធ្វើការសំរេចនៅប៉ុន្មានថ្ងៃ ឬប៉ុន្មានសប្ដាហ៍ខាងមុខ។ ជំនួយមានផ្ដល់សំរាប់
អ្នក ហើយអ្នកមើលថែរបស់អ្នកអាចនឹងផ្ដល់ឱវាទណែនាំជូនអ្នកផងដែរ។*

## ខិតប័ណ្ណនេះរៀបចំឡើង ដើម្បីជួយអ្នកក្នុងការសំរេចអំពីការវះកាត់ពិនិត្យសព

ការសំរេចអំពីការវះកាត់ពិនិត្យសពអាចនឹងមានការលំបាកយ៉ាងខ្លាំង។
នេះគឺប្រការសំខាន់ដែលអ្នកត្រូវធ្វើសេចក្ដីសំរេច ឲ្យបានត្រឹមត្រូវសំរាប់រូបអ្នក និងគ្រួសាររបស់អ្នក។
ត្រូវគិតពិចារណាអំពីអារម្មណ៍បែបណាដែលអ្នក និងគ្រួសាររបស់ អ្នកនឹងមាននៅពេលអនាគត។
ជាពិសេសអ្នកត្រូវគិតថាតើការវះកាត់ពិនិត្យសពអាចនឹងជួយអ្នក និងគ្រួសាររបស់អ្នកឲ្យ
បានយល់ថាហេតុអ្វីបានជាទារករបស់អ្នកស្លាប់។  បុគ្គលិកមន្ទីរពេទ្យនឹងគោរព ហើយជួយគាំទ្រអ្នក
ទោះបីជាអ្នកសំរេច យ៉ាងណាក្ដីអំពីការវះកាត់ពិនិត្យសព។

ការវះកាត់ពិនិត្យសព អាចធ្វើបានលុះត្រាតែមានការយល់ព្រមពីមាតា/បិតាប៉ុណ្ណោះ។

បន្ទាប់ពីអានព័ត៌មាននេះហើយ អ្នកប្រហែលយល់ថាមានប្រយោជន៍ក្នុងការពិភាក្សាអំពីការវះកាត់ពិនិត្យសពជាមួយ
វេជ្ជបណ្ឌិត ឬឆ្មបដែលមើលថែអ្នកក្នុងពេលមានផ្ទៃពោះ ឬជាមួយអ្នកផ្ដល់ឱវាទណែនាំ ឬបុគ្គលិកសង្គមកិច្ច មន្ទីរ
ពេទ្យ។ អ្នកក៏អាចស្នើសុំឲ្យមានពេលថែមទៀតបានដែរដើម្បីគិតអំពីរឿងនេះ ហើយពិភាក្សារជាមួយដៃគូរបស់អ្នក
គ្រួសារ មិត្តភក្ដិ ឬអ្នកដឹកនាំសាសនា។

## តើការវះកាត់ពិនិត្យសពជាអ្វី?

ការវះកាត់ពិនិត្យសព គឺជាការពិនិត្យមើលខាងវេជ្ជសាស្ត្រនៃសាកសពបន្ទាប់ពីការស្លាប់។ វេជ្ជបណ្ឌិតជាអ្នកទទួលរ៉ាប់
រងធ្វើការពិនិត្យសព (តាមធម្មតាគឺអ្នកធ្វើរោគវិនិច្ឆ័យ
ឬវេជ្ជបណ្ឌិតដែលទទួលការហ្វឹកហ្វឺនផ្នែករោគសាស្ត្រក្រោមការ ត្រួតពិនិត្យពីអ្នកធ្វើរោគវិនិច្ឆ័យ)។
អ្នកធ្វើរោគវិនិច្ឆ័យ គឺជាវេជ្ជបណ្ឌិតដែលមានជំនាញការក្នុងការសិក្សាអំពីជម្ងឺ។ ការវះ
កាត់ពិនិត្យសពត្រូវបានធ្វើឡើងដោយមានការគោរព ហើយយកចិត្តទុកដាក់ជាទីបំផុតចំពោះខ្លួនប្រាណទារក។

## តើព័ត៌មានអ្វីខ្លះដែលទទួលបានពីការវះកាត់ពិនិត្យសព?

ការវះកាត់ពិនិត្យសពអាចជាការវះកាត់ពិនិត្យសពពេញលេញ ឬការវះកាត់ពិនិត្យសពត្រឹមកំរិតណាមួយ។
ជំរើសទាំងពីរ ប្រភេទនេះនឹងបានពន្យល់ប្រាប់ជាលំអិតបន្ថែមទៀត។

ការវះកាត់ពិនិត្យសពពេញលេញអាច:

- ជួយអ្នកឲ្យបានដឹងព័ត៌មានបន្ថែមទៀត អំពីលក្ខណៈវេជ្ជសាស្ត្រដែលអាចបណ្តាលឲ្យ ឬនាំឲ្យទារករបស់អ្នកស្លាប់។
- ផ្តល់នូវព័ត៌មានដើម្បីបញ្ជាក់ប្រាប់ ឬបដិសេធនូវការសង្ស័យ ឬមិនសង្ស័យលើលក្ខណៈវេជ្ជសាស្ត្រណាមួយ។ ការនេះអាចជាការសំខាន់សំរាប់អ្នក ឬសមាជិកគ្រួសាររបស់អ្នក ជាពិសេសប្រសិនបើលក្ខណៈរោគទំនងជាឆ្លងតាមពូជ។
- ផ្តល់នូវព័ត៌មានសំរាប់អ្នកវិជ្ជាជីវៈផ្នែកសុខភាព ដែលអាចមានសារសំខាន់ក្នុងការគ្រប់គ្រងចាត់ចែងនៃការមាន ផ្ទៃពោះរបស់អ្នកនៅពេលអនាគត។
- បង្ហាញឲ្យឃើញនូវលក្ខណៈរោគទាំងឡាយ ដែលអាចប៉ះពាល់ដល់ក្មេងឯទៀតក្នុងគ្រួសារ ឬការមានផ្ទៃពោះនៅពេលអនាគត។
- រួមចំណែកដល់ការយល់ដឹងនៃអ្នកទាំងឡាយដែលមើលថែអ្នក ហើយផ្តល់នូវចំណេះដឹងដែលគេអាចយកទៅ ប្រើប្រាស់ដើម្បីជួយដល់មាតា និងទារកទាំងឡាយនៅពេលអនាគត។

ការវះកាត់ពិនិត្យសពត្រឹមកំរិតមិនតែងតែផ្តល់នូវចម្លើយទាំងអស់ អំពីបុព្វហេតុនៃការស្លាប់នោះទេ។

## តើការវះកាត់ពិនិត្យសពត្រឹមកំរិតជាអ្វី?

ការវះកាត់ពិនិត្យសពត្រឹមកំរិតអាចទាក់ទិននឹងការពិនិត្យមើលតែផ្នែករាងកាយខាងក្រៅប៉ុណ្ណោះ ឬការពិនិត្យមើលផ្នែក ក្រៅខ្លួន និងការធ្វើតេស្តខ្លះៗនូវគំរូជាលិកាតូច ឬការធ្វើតេស្តឈាម ឬការពិនិត្យមើលផ្នែករាងកាយក្រៅខ្លួន ព្រមជាមួយនឹងការពិនិត្យមើលផ្នែកក្នុងខ្លួនដែលមានកំណត់ត្រឹមតែផ្នែកណាមួយ។

ការវះកាត់ពិនិត្យសពត្រឹមកំរិតនឹងពុំផ្តល់នូវព័ត៌មានលំអិត ដូចគ្នានឹងការវះកាត់ពិនិត្យសពពេញលេញទេ ហើយតែងតែ អាចមានចន្លោះខ្វះខាតណាមួយដែលមិនបានរំពឹងទុក។ ទោះជាយ៉ាងណាក្តី ការវះកាត់ពិនិត្យសពត្រឹមកំរិតក៏អាចផ្តល់នូវ ព័ត៌មានដ៏មានតម្លៃដែរ។

## តើមានអ្វីកើតឡើងចំពោះទារករបស់អ្នក នៅពេលវះកាត់ពិនិត្យសព?

វេជ្ជបណ្ឌិតដែលតាមធម្មតាជាអ្នកធ្វើរោគវិនិច្ឆ័យ បំពេញកិច្ចការវះកាត់ពិនិត្យសព។ វេជ្ជបណ្ឌិតនោះនឹងពិនិត្យមើលឡើងវិញដោយប្រុងប្រយ័ត្ននូវកំណត់ត្រាផ្នែកវេជ្ជសាស្ត្រ បន្ទាប់មកទទួលរ៉ាប់រងធ្វើការពិនិត្យយ៉ាងហ្មត់ចត់លើទារករបស់អ្នក។ ការវះកាត់ពិនិត្យសពពេញលេញ មាននូវរួមទាំងការពិនិត្យមើលផ្នែករាងកាយខាងក្រៅដោយប្រុងប្រយ័ត្ន ជាមួយនឹងការវាស់ស្ទង់ ក៏ដូចជាការពិនិត្យមើលសរីរាង្គខាងក្នុងដែរ។ ការឆ្លុះមើលដោយប្រើកាំរស្មីអិក្ស និងការថតរូប អាចធ្វើឡើងដើម្បីជួយក្នុងការធ្វើរោគវិនិច្ឆ័យ ឬដើម្បីកំណត់នូវមូលហេតុនៃការស្លាប់។

ការវះកាត់ពិនិត្យសពពេញលេញត្រូវធ្វើឡើង ហាក់បីដូចជាទារកកំពុងទទួលការវះកាត់នោះដែរ។ តាមធម្មតាអ្នកធ្វើរោគ វិនិច្ឆ័យត្រូវវះកាត់ពីរកន្លែង គឺមួយនៅទទឹងផ្នែកខាងក្រោយក្បាល ហើយមួយកន្លែងទៀតនៅពីមុខដងខ្លួន។ ការនេះ អនុញ្ញាតឲ្យអ្នកធ្វើរោគវិនិច្ឆ័យពិនិត្យមើលសរីរាង្គសំខាន់ៗ និងរកមើលអ្វីដែលមិនប្រក្រតី ឬរកមើលនូវសញ្ញាអ្វីមួយ ដែលជាដើមហេតុនៃការស្លាប់។ តាមធម្មតាគេយកគំរូជាលិកាដ៏តូច និងវត្ថុរាវទៅពិនិត្យមើលនៅក្រោមអតិសុខុម ទស្សន៍ ហើយនិងធ្វើតេស្តផ្សេងៗទៀតដូចជាការរកមើលកន្លែងមានឆ្លងមេរោគ ឬក្នុងករណីយពិសេសគឺធ្វើតេស្តខាង

តំណពូជ។ ជួនកាលជាចាំបាច់ដែលអ្នកធ្វើពោតវិនិច្ឆ័យត្រូវរក្សាទុកនូវសរីរាង្គទាំងមូល (តាមធម្មតាខួរក្បាល ឬបេះដូង) សំរាប់ការពិនិត្យមើលបន្ថែមទៀត ដើម្បីធ្វើតេស្តរកមើលសញ្ញាទាំងឡាយនៃជម្ងឺ ឬមុខរបួសដែលមិនបង្ហាញឲ្យឃើញ ភ្លាមៗ។

គេមិនអាចដឹងមុនចំពោះសារសំខាន់នៃការថែរក្សាទុកនូវសរីរាង្គពិសេសណាមួយបានឡើយ រហូតទាល់តែគេ វះកាត់ពិនិត្យសព។ នៅក្នុងករណីខ្លះ ការពន្យាពេលរយៈពេលខ្លីនៅក្នុងការធ្វើបុណ្យបញ្ចុះសពអាចគ្រប់គ្រាន់ ក្នុងការរង់ ចាំទទួលយកសរីរាង្គមកដាក់ក្នុងខ្លួនប្រាណសពវិញ មុននឹងលើកសាកសពយកទៅបញ្ចុះ ឬបូជា។ ប្រសិនបើការនេះ មិនអាចធ្វើបានទេ អ្នកអាចធ្វើការសំរេចចង់ឲ្យគេប្រគល់សរីរាង្គរបស់ទារកត្រឡប់មកអ្នកវិញ ឬទៅឲ្យជនណាម្នាក់ដែល អ្នកចាត់តាំងដើម្បីធ្វើការបញ្ចុះ ឬបូជាដោយឡែក ឬឲ្យអង្គការសុខភាពសាធារណៈរៀបចំទុកដាក់ (តាមធម្មតាដោយការ បូជា) ស្របតាមផ្លូវច្បាប់។ វេជ្ជបណ្ឌិតរបស់អ្នកនឹងពន្យល់បន្ថែមយ៉ាងលំអិតអំពីដំណើរការទាំងនេះ។

## តើមានអ្វីកើតឡើងបន្ទាប់ពីការវះកាត់ពិនិត្យសព?

នៅពេលការពិនិត្យមើលបានធ្វើចប់សព្វគ្រប់ នុះគេនឹងជូតសំអារទារក ហើយដេរភ្ជិតស្នាមវះកាត់វិញ។ នៅក្នុងករណី ភាគច្រើន ពេលណាទារកបានស្លៀកពាក់រួចហើយ គេពុំសូវសម្គាល់ឃើញសញ្ញានៃការវះកាត់ទាំងនោះទេ។ ជាធម្មតា ក្រោយពីពេលការវះកាត់ពិនិត្យសពហើយ អ្នក និងគ្រួសាររបស់អ្នកអាចមើល ហើយលើកកាន់ទារករបស់អ្នកឡើង វិញ។ ភិនភាគខាងក្រៅ និងពណ៌សម្បុរស្បែករបស់ទារកអ្នកនឹងផ្លាស់ប្តូរក្រោយពីការស្លាប់ ហើយខ្លួនប្រាណក៏មាន សភាពខុសប្លែកដែរនៅពេលកាន់ពាល់។ ការផ្លាស់ប្តូរទាំងនេះកើតមានឡើងតាមធម្មជាតិ ក្រោយការស្លាប់ ហើយពុំ ទាក់ទងអ្វីទៅនឹងការវះកាត់ពិនិត្យសពនោះទេ។

## តើខ្ញុំត្រូវបង់ប្រាក់សំរាប់ការវះកាត់ពិនិត្យសពឬ?

តាមធម្មតា ពុំមានបង់ថ្លៃទាក់ទិននឹងការវះកាត់ពិនិត្យសពទេ ទោះបីជាយ៉ាងណាក្តី នេះគឺជាការសំខាន់ដែលអ្នកត្រូវ ពិភាក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក ឬអ្នកតំណាងមន្ទីរពេទ្យអំពីតម្លៃណាមួយដែលអាចមាន មុននឹងអ្នកផ្តល់ការយល់ ព្រម។ ប្រសិនបើអ្នក ក៏ប៉ុន្តែមិនមែនមន្ទីរពេទ្យទេ ដែលជាអ្នកស្នើសុំឲ្យមានការវះកាត់ពិនិត្យសព នោះប្រហែលមានការ បង់ថ្លៃទាក់ទិននឹងការដឹកជញ្ជូនទារកទៅមន្ទីរពេទ្យដែលផ្តល់ការវះកាត់ពិនិត្យសពទារក។ ជំនួយផ្នែកប្រាក់កាសទាក់ទិន នឹងថ្លៃបញ្ចុះសពទារករបស់អ្នក ឬការរក្សាទុកនូវសរីរាង្គ អ្នកអាចទទួលយកបានតាមរយៈមន្ទីរពេទ្យ ឬតាមរយៈកិច្ចបំរើ ផ្នែកសុខភាពតាមតំបន់។

## ហេតុអ្វីបានជាតម្រូវឲ្យមានការយល់ព្រមដើម្បីធ្វើការវះកាត់ពិនិត្យសព?

គេត្រូវឲ្យមានការយល់ព្រមជាលាយលក្ខណ៍អក្សរអំពីអ្នក មុននឹងគេធ្វើការវះកាត់ពិនិត្យសពទារករបស់អ្នក។ នេះគឺតម្រូវ ការផ្លូវច្បាប់។ អ្នកវិជ្ជាជីវៈផ្នែកសុខភាពនឹងមកជួយអ្នក ហើយស្នើសុំការយល់ព្រមអំពីអ្នកដើម្បីធ្វើការវះកាត់ពិនិត្យសព។

អ្នកមានសិទ្ធិក្នុងការជ្រើសរើសថាតើត្រូវផ្តល់ការយល់ព្រមដើម្បីការវះកាត់ពិនិត្យសពនោះ ឬយ៉ាងណា។ ការយល់ព្រម របស់អ្នកត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

ដោយហេតុថា ការវះកាត់ពិនិត្យសពអាចបង្ហាញឲ្យដឹងអំពីព័ត៌មានផ្នែកតំណពូជដែលទាក់ទិននឹងឪពុក ឬម្តាយផ្ទាល់ ដែលផ្តល់កំណើតកូន គេក៏ត្រូវឲ្យមានការយល់ព្រមដោយគ្មានការជំទាស់ពីឪពុក ឬម្តាយម្ខាងទៀតផងដែរ។

ផ្សេងពីនេះវិញ អ្នកអាចជ្រើសរើសឲ្យជនម្នាក់ទៀតធ្វើការសំរេចជំនួសអ្នក ទាក់ទិននឹងការអនុញ្ញាតយល់ព្រមឲ្យធ្វើការ វះកាត់ពិនិត្យសព ហើយនិងការវះយកប្រើនូវជាលិកាសំរាប់គោលបំណងនៃការវះកាត់ពិនិត្យសព។ អ្នកនឹងត្រូវបានគេស្នើសុំឲ្យបំពេញសំណុំបែបបទមួយ ប្រសិនបើអ្នកប្រាថ្នាចង់ឲ្យនរណាម្នាក់ទៀតធ្វើការសំរេចជំនួសអ្នកក្នុងរឿងនេះ។

អ្នកត្រូវតែយល់ថា ដោយសារការសំរេចបែបនេះមានន័យថា អ្នកបានអនុញ្ញាតឲ្យជនផ្សេងទៀតធ្វើសេចក្តីសំរេចអំពីទារករបស់អ្នកហើយ។

## តើមានអ្វីកើតឡើងបន្ទាប់ពីបានផ្តល់ការយល់ព្រមដើម្បីធ្វើការវះកាត់ពិនិត្យសព?

ការវះកាត់ពិនិត្យសពនឹងបានប្រព្រឹត្តទៅយ៉ាងឆាប់បំផុត ដែលអាចធ្វើទៅបាន បន្ទាប់ពីមានការយល់ព្រម។ មានពេលខ្លះ កាលណាមានគេសង្ស័យលើលក្ខណៈរោគណាមួយ សំណាកមួយចំនួនត្រូវគេយកភ្លាមបន្ទាប់ពីទារកបានស្លាប់ដើម្បី គេអាចធ្វើតេស្តឲ្យបានត្រឹមត្រូវ។ នៅក្នុងករណីនេះ វេជ្ជបណ្ឌិតរបស់អ្នកនឹងពិភាក្សារឿងនេះជាមួយអ្នក។ ប្រសិនបើអ្នកចង់ឃើញទារករបស់អ្នកមុនការវះកាត់ពិនិត្យសព សូមប្រាប់វេជ្ជបណ្ឌិត ឬឆ្មបរបស់អ្នកឲ្យបានដឹងដើម្បីឲ្យគេរៀបចំការពន្យាពេលវះកាត់ពិនិត្យសព។ ការវះកាត់ពិនិត្យសពអាចពន្យាបានក្នុងរយៈពេលខ្លី ក៏ប៉ុន្តែត្រូវបានគេបានណែនាំឲ្យមានក្នុងរយៈពេល៤៨ម៉ោងប៉ុណ្ណោះ។

## តើពេលណាខ្ញុំនឹងបានទទួលដំណឹងអំពីលទ្ធផលនៃការវះកាត់ពិនិត្យសព?

របាយការណ៍ដំបូងអំពីការវះកាត់ពិនិត្យសព អាចធ្វើបានក្នុងរយៈពេលប៉ុន្មានថ្ងៃនៃការវះកាត់ពិនិត្យសព។ ក៏ប៉ុន្តែលទ្ធផលនៃការធ្វើតេស្តខ្លះត្រូវរង់ចាំ រហូតដល់ទៅ១២អាទិត្យ ដែលនៅពេលនោះរបាយការណ៍ចុងបញ្ចប់នឹងបានរៀបចំឡើង។

អ្នកគួរតែពិចារណាថាតើជាការប្រសើរ ឬយ៉ាងណាទេ ដែលអ្នកត្រូវទទួលរបាយការណ៍ស្តីពីការវះកាត់ពិនិត្យសពតាមរយៈអ្នកមើលថែចម្បងរបស់អ្នក ឬតាមរយៈវេជ្ជបណ្ឌិតប្រចាំគ្រួសាររបស់អ្នក ឬតាមរយៈវេជ្ជបណ្ឌិតម្នាក់ផ្សេងទៀត ដែលអាចពិភាក្សាអំពីរបាយការណ៍នោះជាមួយអ្នក។ អ្នកគួររៀបចំឲ្យមានពេលដើម្បីជួបជាមួយវេជ្ជបណ្ឌិតទាំងនេះណាមួយ ដើម្បីពិភាក្សាអំពីរបាយការណ៍ និងអំពីភាពស្មុគ្រស្មាញណាមួយអាចកើតមានដល់អ្នក ឬគ្រួសាររបស់អ្នក ដោយហេតុថាវាអាចមានពាក្យបច្ចេកទេសនៅក្នុងរបាយការណ៍នោះ។

## ការរក្សាទុក និងការប្រើប្រាស់នូវសរីរាង្គ និងជាលិកាសំរាប់គោលបំណងផ្នែកព្យាបាលរោគវេជ្ជសាស្រ្ត និងវិទ្យាសាស្រ្ត

នៅពេលអ្នកវិជ្ជាជីវៈផ្នែកសុខភាពមកជួបអ្នក ដើម្បីទទួលយកការយល់ព្រមក្នុងការវះកាត់ពិនិត្យសព អ្នកនឹងត្រូវគេស្នើ សុំឲ្យគិតពិចារណាលើការអនុញ្ញាតឲ្យប្រើប្រាស់សរីរាង្គ ឬជាលិកាទារករបស់អ្នកសំរាប់គោលបំណងផ្សេងទៀត (ដូចជាការស្រាវជ្រាវ វេជ្ជសាស្រ្ត ឬវិធីព្យាបាលរោគ) ដែលពុំមែនជាផ្នែកនៃការវះកាត់ពិនិត្យសព។

ប្រសិនបើអ្នកយល់ព្រមឲ្យគេរក្សាទុកសរីរាង្គ និង/ឬជាលិកាទារករបស់អ្នកសំរាប់ការស្រាវជ្រាវ វេជ្ជសាស្រ្ត ឬពិធីព្យាបាលរោគ តាមធម្មតាសរីរាង្គ និងជាលិកានោះនឹងត្រូវគេរក្សាទុកក្នុងរយៈពេលដែលតម្រូវប៉ុណ្ណោះ។ រយៈពេលនៃការរក្សាទុកសរីរាង្គ ឬជាលិកាសំរាប់ការស្រាវជ្រាវ អាចត្រូវគេចុះបញ្ជាក់នៅក្នុងព័ត៌មានជាក់លាក់ស្តីពីគំរោងស្រាវជ្រាវ ឬអ្នកអាចសួររកព័ត៌មានបន្ថែមទៀតបាន។

អ្នកពុំចាំបាច់ត្រូវតែយល់ព្រមឲ្យមានការប្រើប្រាស់នូវសរីរាង្គ និងជាលិកាសំរាប់គោលបំណងវិធីព្យាបាលរោគវេជ្ជសាស្រ្ត ឬវិទ្យាសាស្រ្តទេ។ ការវះកាត់ពិនិត្យសពនៅតែអាចប្រព្រឹត្តទៅបាន ទោះបីជាអ្នកមិនយល់ព្រមឲ្យគេប្រើប្រាស់ជាលិកាសំរាប់គោលបំណងទាំងនេះក៏ដោយ។ ប្រសិនបើអ្នកយល់ព្រមវិញនោះ ការនោះត្រូវអនុវត្តន៍ចំពោះតែជា លិកាដែលគេយកប្រើសំរាប់គោលបំណងនៃការវះកាត់ពិនិត្យសពប៉ុណ្ណោះ។ នេះមិនមានន័យថានឹងមានការវះកាត់យក សរីរាង្គ និងជាលិកាឯទៀតនោះទេ។

## ព័ត៌មាន និងជំនួយផ្គត់ផ្គង់សំរាប់អស់អ្នកដែលមានអ្នកណាស្លាប់ចោល

ប្រសិនបើអ្នកមានសំនួរណាមួយ វេជ្ជបណ្ឌិត ឆ្មប អ្នកសម្របសម្រួលការវះកាត់ពិនិត្យសព ឬបុគ្គលិកសង្គមកិច្ចនឹងខិតខំផ្តល់ចម្លើយជូនអ្នក។ អ្នកវិជ្ជាជីវៈផ្នែកសុខភាពអាចផ្តល់ព័ត៌មានជូនអ្នក អំពីក្រុមជំនួយដើម្បីជួយអ្នកឆ្លងកាត់ពេល កំពុងមានទុក្ខនេះ។

SIDS and Kids NSW (រួមបញ្ចូល SANDS) ផ្តល់កិច្ចបំរើជំនួយផ្គត់ផ្គង់សំរាប់អ្នកទាំងឡាយដែលមានអ្នកណាស្លាប់ចោល ទៅដល់គ្រួសារដែលជួបប្រទះនឹងការស្លាប់នៃទារករបស់ខ្លួន។ ដើម្បីទទួលយកជំនួយផ្គត់ផ្គង់ និងព័ត៌មាន សូមទូរស័ព្ទលេខ 02 9818 8400 ទូរស័ព្ទឥតគិតថ្លៃលេខ 1800 651 186 ឬអាចទទួលយកព័ត៌មានតាម វ៉ិបសាយ www.sidsandkids.org។

## សង្ខេប:

- ការវះកាត់ពិនិត្យសពគឺជាការពិនិត្យខាងវេជ្ជសាស្រ្តដ៏សំខាន់មួយ ដើម្បីជួយរកចម្លើយថាហេតុអ្វីបានជាទារករបស់អ្នកស្លាប់ ហើយដើម្បីបំបាត់ចេញនូវលក្ខណៈរោគ ឬរោគឆ្លងតាមពូជដែលអាចព្យាបាលបាន ពីការមានផ្ទៃពោះនៅពេលអនាគត។
- ប្រសិនបើអ្នកមានសំនួរបន្ថែមទៀតអំពីការវះកាត់ពិនិត្យសព ការនេះអាចជួយអ្នកប្រសិនបើអ្នកនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នក ឆ្មប បុគ្គលិកសង្គមកិច្ច ឬអ្នកដឹកនាំសាសនា ឬសមាជិកឯទៀតរបស់គ្រួសារអ្នក។
- ប្រសិនបើអ្នកមិនចង់ឲ្យមានការវះកាត់ពិនិត្យសពពេញលេញសំរាប់ទារករបស់អ្នកទេ សូមនិយាយប្រាប់វេជ្ជបណ្ឌិតរបស់អ្នកអំពីលទ្ធភាពនៃការធ្វើតេស្តតាមរបៀបផ្សេងទៀត ដែលអាចផ្តល់ដល់អ្នកនូវព័ត៌មានស្តីអំពីបុព្វហេតុនៃការស្លាប់។
- ការវះកាត់ពិនិត្យសព មិនអាចប្រព្រឹត្តទៅបានឡើយ ដោយគ្មានការយល់ព្រមជាលាយលក្ខណ៍អក្សរអំពីអ្នក។
- ការវះកាត់ពិនិត្យសពនៅមន្ទីរពេទ្យ នឹងប្រព្រឹត្តទៅយ៉ាងឆាប់បំផុត ដែលអាចធ្វើទៅបាន បន្ទាប់ពីមានការយល់ ព្រម។ តាមធម្មតាការនេះតែងប្រព្រឹត្តទៅក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីការស្លាប់។
- បើសិនជាអ្នកចង់ អ្នកអាចជួប ហើយលើកបីទារករបស់អ្នកម្តងទៀត បន្ទាប់ពីការវះកាត់ពិនិត្យសពរួច។
- លទ្ធផលនៃវះកាត់ពិនិត្យសព តាមធម្មតាត្រូវគេបញ្ជូនទៅឲ្យវេជ្ជបណ្ឌិតក្នុងរយៈពេល៦-១២អាទិត្យ។

## លេខទូរស័ព្ទទាក់ទង

អ្នកសំរបសំរួលការវះកាត់ពិនិត្យសព ..............................................................................................

លេខទូរស័ព្ទ ..............................................................................................

វេជ្ជបណ្ឌិត ..............................................................................................

លេខទូរស័ព្ទ ..........................................................................................................................................................................

បុគ្គលិកសង្គមកិច្ច ...................................................................................................................................................................

លេខទូរស័ព្ទ ..........................................................................................................................................................................

សាសនាចារ្យនៅតាមមន្ទីរពេទ្យ ......................................................................................................................................

លេខទូរស័ព្ទ .........................................................................................................................................................................